# ព្រះវិហារវត្តនគរបាជ័យ

វត្តនគរបាជ័យ គឺជាបូជនីយដ្ឋានព្រះពុទ្ធសាសនាដ៏ល្បីស្ថិតនៅក្នុងខេត្តកំពង់ចាម ហើយបានកសាងនៅក្នុងបរិវេណប្រាសាទនគរបាជ័យ ដែលជាប្រាសាទឧទ្ទិសថ្វាយព្រះពុទ្ធសាសនាមហាយាននៃរាជ្យព្រះបាទជ័យវរ្ម័នទី៧។ បច្ចុប្បន្ននៅក្នុងបរិវេណប្រាសាទនេះដែរគេឃើញវត្តពីរ វត្តមួយស្ថិតនៅជ្រុងអាគ្នេយ៍ ខាងក្រៅកំពែងប្រាសាទហៅថា"វត្តនគរបាជ័យក្រៅ"។ ចំណែកវត្តមួយស្ថិតក្នុងកំពែងប្រាសាទហៅថា"វត្តនគរបាជ័យក្នុង" ឬអ្នកផងហៅជាទូទៅថា"វត្តនគរបាជ័យ"។ ចំពោះអ្នកស្រុកកំពង់ចាម ភាគច្រើននិយមហៅថា "វត្តអង្គរ" តែពុំដឹងថាពាក្យនេះហៅសំដៅវត្តនៅខាងក្រៅ ឬវត្តនៅខាងក្នុងប្រាសាទ។ ប៉ុន្តែតាមរយៈរូបថតឯកសារសម័យបារាំង គេហៅវត្តខាងក្នុងប្រាសាទថា "វត្តនគរ" ហើយបានចុះលេខសម្គាល់គឺ IK 85។ ចំណែកឯកសារសម័យសង្គមរាស្រ្តនិយមក៏ហៅវត្តនេះថា "វត្តនគរ" ដែរ។[1] ដូច្នេះនៅក្នុងអត្ថបទនេះខ្ញុំសូមរៀបរាប់ចំពោះវត្តស្ថិតក្នុងកំពែងប្រាសាទដែលគេហៅទូទៅថា "វត្តនគរបាជ័យ" ឬ "វត្តនគរ" តែប៉ុណ្ណោះ (រូបលេខ១)។



រូបលេខ១ ទិដ្ឋភាពទូទៅនៃវត្តនគរបាជ័យ (រូបថត៖ គឹម បញ្ញារតន៍, AMS OneMinute)

[1] នរោត្តម សីហនុ, ១៩៥៥-១៩៦៥, ទំ.២៦២-២៦៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើផ្អែកតាមឯកសារសម័យបារាំង គេឃើញមានរូបថត២សន្លឹកដែលបញ្ជាក់ថាជាព្រះវិហារវត្តនគរបាជ័យ។ រូប១សន្លឹកថតនៅឆ្នាំ១៩៣៥ ថតសំដៅទៅប្រាង្គកណ្តាលប្រាសាទ ដែលបានកែរួចស្រេចជាទម្រង់ចេតិយ ហើយគេអាចមើលឃើញជាប់ជ្រុងបន្តិចនៃព្រះវិហារ មានដំបូលលម្អដោយនាគបែង ក្បាច់រង់ស្បូវ តែពុំមានជញ្ជាំង (រូបលេខ២)។ ចំណែករូបមួយទៀត ថតក្នុងឆ្នាំ១៩៣៦ បង្ហាញយ៉ាងច្បាស់នូវព្រះវិហារជហ្វា៦ ដំបូលជ្រាលចុះសងខាង៤ថ្នាក់ មានគ្រឿងលម្អដំបូលយ៉ាងវិចិត្រ ព្រមទាំងមានហោជាង២ថ្នាក់ប្រកបដោយក្បាច់លម្អយ៉ាងរស់រវើក។ សោតឯជញ្ជាំងព្រះវិហារនេះ ទំនងជាជញ្ជាំងក្តារហើយដែលមានទ្វារចេញចូលធំៗតាមទិសទាំង៤។ រូបទី២នេះ គេពុំឃើញមានជាប់ប្រាង្គប្រាសាទ ឬចេតិយនៅក្បែរសោះឡើយ (រូបលេខ៣)។ ប្រការនេះនាំឱ្យគេស្មានបានថា រូបទី១ ជាព្រះវិហារវត្តនគរបាជ័យក្នុង ដែលគ្មានជញ្ជាំង ហើយរូបទី២ ជាព្រះវិហារវត្តនគរបាជ័យក្រៅ ដែលទំនងជាស្ថិតនៅលើស្នាកស្នាមខឿនថ្មបាយក្រៀម នៃផ្នែកខាងជើងព្រះវិហារថ្មីវត្តនគរបាជ័យក្រៅក្នុងគ្រាបច្ចុប្បន្ន។



*រូបលេខ២-៣ រូបថតឯកសារព្រះវិហារវត្តនគរបាជ័យមើលតាមឯកសារឆ្នាំ១៩៣៥-១៩៣៦*

ដោយឡែក បើត្រឡប់មកមើលព្រះវិហារសព្វថ្ងៃនៃវត្តនគរបាជ័យក្នុង ដែលខ្ញុំសូមលើកមករៀបរាប់នេះ គឺជាប្រភេទព្រះវិហារជហ្វា៤ និងមានរចនាសម្ព័ន្ធទូទៅនៃសំណង់កសាងពីបេតុង។ លក្ខណៈស្ថាបត្យកម្មព្រះវិហារនេះដូចគ្នានឹងឯកសាររូបថតមួយសន្លឹក

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ទៀតដែលថតពីចម្ងាយ មើលឃើញទម្រង់ដំបូលព្រះវិហារពេញលេញជាព្រះវិហារជហ្វា ៤ ប្រក់ក្បឿងស្រកាលេញ និងមានហោជាងក្ដារលាតឥតក្បាច់រចនាឡើយ (រូបលេខ២៤)។ បើពិនិត្យលម្អិត ព្រះវិហារក្នុងរូបលេខ២២និងព្រះវិហារក្នុងរូបលេខ២៤ ប្រហែលជាព្រះវិហារតែមួយនៃវត្តនគរបាជ័យក្នុង ជាព្រះវិហារគ្មានជញ្ជាំងដូចការរៀបរាប់ខាងលើ។ ប៉ុន្តែបើមើលព្រះវិហារសព្វថ្ងៃនៅវត្តនគរបាជ័យក្នុង គេឃើញជាព្រះវិហារជហ្វា៤ដូចគ្នាដែរ តែដំបូលប្រក់គ្រឿងរលោងពណ៌លឿងនិងបៃតង (អ្នកស្រុកខ្លះហៅថាក្បឿងរាំង)។ ចំណែកឯហោជាង គឺជាសិល្បៈក្បាច់ពុម្ពស៊ីម៉ងត៍ (រូបលេខ២៥)។



រូបលេខ២៤-៥ រូបថតឯកសារព្រះវិហារវត្តនគរបាជ័យមើលតាមឯកសារឆ្នាំ១៩៣៥-១៩៣៦

ព្រះវិហារសព្វថ្ងៃ ជាសំណង់បេតុង ចំហៀងជុំវិញបើកចំហដើងជញ្ជាំង ហើយនៅផ្នែកខាងលិចព្រះវិហារ អ្នកស្រុកបានកែប្រាង្គកណ្ដាលនៃប្រាសាទធ្វើជាទម្រង់ចេតិយ។ គេយល់ថាការកែសម្រួលប្រាង្គកណ្ដាលនៃប្រាសាទមកធ្វើជាចេតិយនេះ កើតឡើងតាំងពីសតវត្សទី១៦ ហើយផ្នែកខាងក្នុងតម្កល់ព្រះពុទ្ធបដិមាត្រឡែងកែង (ឬអ្នកខ្លះហៅថា "ព្រះពុទ្ធបដិមាចតុទិស")។[2] មិនតែប៉ុណ្ណោះនៅលើជញ្ជាំងព្រះវិហារបច្ចុប្បន្ន មានចំណារមួយផ្ទាំងបញ្ជាក់ថា ព្រះវិហារនេះកសាងតាំងពីឆ្នាំមមី ទោស័ក ពុទ្ធសករាជ២៤៧៣ បានសាងតែគ្រឹះកណ្ដាលប៉ុណ្ណោះក៏អាក់ខានទៅ រហូតដល់ឆ្នាំថោះ ត្រីស័ក ពុទ្ធសករាជ ២៤៩៤ ទើបបានធ្វើបាំងសាច(ជញ្ជាំង)បន្តមកទៀត អស់ប្រាក់ចំនួន៧៩៥៦៦រៀល (រូបលេខ២៦-៧)។ បើយោងខ្លឹមសារចំណារនោះបានសេចក្ដីថា ព្រះវិហារសព្វថ្ងៃនៅវត្តនគរ

[2] អ៊ឹង មរកត, ២០១៧, ទំ.១៩-២១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បាជ័យក្នុង កសាងនៅអំឡុងឆ្នាំ១៩៣០ រហូតមកដល់ឆ្នាំ១៩៥១ ទើបចាប់ផ្ដើមកសាងជញ្ជាំង គឺហាក់ដូចជាស្របទៅនឹងឯកសាររូបថតឆ្នាំ១៩៣៥។ រីឯរចនាសម្ព័ន្ធដំបូល និងហោជាងសព្វថ្ងៃប្រហែលជួសជុលកែលម្អនៅក្រោយសម័យសង្គ្រាម។




រូបលេខ៦-៧ ព្រះវិហារវត្តនគរបាជ័យសព្វថ្ងៃ និងចំណារលើជញ្ជាំងព្រះវិហារ

ចំពោះផ្នែកខាងក្នុងនៃព្រះវិហារ នៅផ្នែកជញ្ជាំងខាងលិច ដែលភ្ជាប់ទៅនឹងប្រាង្គចេតិយ មានតម្កល់ព្រះពុទ្ធបដិមាមួយព្រះអង្គក្នុងកាយវិការសមាធិ(ធ្យានមុទ្រា)ទ្រង់ផ្ទែនព្រះហស្តដាក់ត្រួតលើគ្នា ព្រះនេត្របិទ។ ព្រះពុទ្ធបដិមាអង្គនេះ ប្រៀបដូចជាព្រះជីវ៍នៅតាមព្រះវិហារទូទៅដែរ តែតម្កល់ក្នុងប្រាង្គចេតិយ ដោយមានផ្នែកខាងមុខនៃប្រាសាទដែលមានសសរផ្ដោប សសរពេជ្រ ផ្ដែរ និងហោជាងលយចូលមកក្នុងព្រះវិហារ បៀបដូចជាសន្ទិយាខាងមុខព្រះជីវ៍ (រូបលេខ៨)។ ព្រះពុទ្ធបដិមានេះ តម្កល់បែរខ្នងទល់គ្នានឹងព្រះពុទ្ធបដិមា៣អង្គផ្សេងទៀត គង់ក្នុងកាយវិការផ្សេងៗ បែរទៅទិសខាងត្បូង ខាងលិច និងខាងជើងស្របតាមទ្វារនីមួយៗនៃប្រាង្គចេតិយ។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺចម្លាក់នៅលើហោជាងដែលលយចូលក្នុងព្រះវិហារនេះ ជាសាច់រឿងពុទ្ធប្រវត្តិបង្ហាញត្រង់ព្រះអង្គផ្ចាញ់មារ លាបរំលេចពណ៌លឿង។ អ្នកស្រាវជ្រាវខ្លះយល់ថា ចម្លាក់នេះធ្លាក់នៅក្នុងសតវត្សទី១៦ លើប្រាសាទដែលសាងតាំងពីសតវត្សទី១២។[3]

[3] ព្រាប ចាន់ម៉ារ៉ា, ២០១៥, ទំ.២៤៣០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




*រូបលេខ៨ ព្រះពុទ្ធបដិមាក្នុងព្រះវិហារវត្តនគរបាជ័យក្នុង*

ចំណែកឯសិល្បៈគំនូរខាងក្នុងព្រះវិហារ បើមើលលើចំណារមួយផ្ទាំងទៀតនៅលើជញ្ជាំង មានសេចក្តីបញ្ជាក់ពីកាលបរិច្ឆេទកសាងគំនូរថា គំនូរព្រះវិហារនេះចាប់ផ្តើមគូរពីឆ្នាំមមី ឆស័ក ពុទ្ធសករាជ២៤៩៧ រហូតដល់ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ២៤៩៩ ទើបបានហើយ អស់ប្រាក់ឈ្នួលជាងចំនួន១១.៧១៦១៛ បានពីសទ្ធាចូលរួមរបស់ពុទ្ធបរិស័ទជិតឆ្ងាយ (រូបលេខ៩)។ តាមរយៈសេចក្តីនេះអាចបញ្ជាក់បានថាគំនូរក្នុងព្រះវិហារកសាងឡើងនៅក្នុងឆ្នាំ១៩៥៤ ពោលគឺក្រោយកសាងជញ្ជាំងរួចប្រហែល៤ឆ្នាំ។ ប៉ុន្តែបើពិនិត្យមើលលើលក្ខណៈទូទៅនៃគំនូរក្នុងព្រះវិហារនេះក្នុងពេលបច្ចុប្បន្ន គឺប្រហែលជាសិល្បៈគំនូរថ្មី គូរឡើងវិញក្នុងរវាងទសវត្សទី៩០ ហើយគូរតាមសាច់រឿងដើម(ឆ្នាំ១៩៥៤) ដ្បិតចំណងជើងគំនូរភាគច្រើនមានទម្រង់អក្សរ និងពាក្យពេចន៍បែបបុរាណ។ ទន្ទឹមនឹងនោះ បើផ្ទៀងផ្ទាត់ឈ្មោះ និងប្រាក់សទ្ធាសាងគំនូរនីមួយៗក៏ប្លែកគ្នាដែរ (រូបលេខ១០-១២)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សាច់រឿងដែលគូរបង្ហាញមានទាំងលើជញ្ជាំងជុំវិញ លើពិតាន និងលើហប់ខ្យល់។ ខ្លឹមសារជាចម្បងទាក់ទងអន្ទើសំខាន់ៗនៃរឿងពុទ្ធប្រវត្តិ និងរឿងជាតក។ ប៉ុន្តែតាមសង្កេតនៅលើជញ្ជាំងជុំវិញគូររឿងពុទ្ធប្រវត្តិ និងរឿងជាតក ហើយនៅលើពិតាន គូរបង្ហាញពាក់ព័ន្ធនឹងអន្ទើនានានៅក្នុងឋានសួគ៌ និងព្រះអាទិត្យ ព្រះចន្ទ្រ ឬសត្វផ្សេងៗក្នុងទេពកថា។ រីឯនៅតាមសសរនីមួយៗ គេគូរក្បាច់លម្អ លាយឡំដោយរូបនាគ និងសត្វផ្សេងៗ។



រូបលេខ៩-១២ ផ្ទាំងចំណារកសាងគំនូរ និងផ្នែកខ្លះនៃគំនូរសព្វថ្ងៃនៅព្រះវិហារវត្តនគរបាជ័យ

ជារួមមកព្រះវិហារវត្តនគរបាជ័យ គឺជាបូជនីយដ្ឋានព្រះពុទ្ធសាសនាសម័យទំនើប ដែលបានកសាងឡើងក្នុងបរិវេណប្រាសាទពុទ្ធសាសនាសតវត្សទី១២។ បើរាប់តាំងពីការកែប្រែប្រាង្គកណ្តាលទៅជាចេតិយនៅសតវត្សទី១៦ ការសាងសង់គ្រឹះ និងជញ្ជាំងព្រះវិហារចន្លោះឆ្នាំ១៩៣០ ដល់១៩៥១ រហូតដល់ការរចនាគំនូរពុទ្ធ ក្នុងទសវត្ស១៩៥០ និងការជួសជុលឡើងវិញនៅពេលក្រោយ បានបង្ហាញយ៉ាងច្បាស់ពីការវិវត្តមុខងារសំណង់បុរាណ និងគំនិតនៃការថែរក្សាបុរាណដ្ឋានទៅតាមសម័យកាល៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

នរោត្តម សីហនុ

១៩៥៥-១៩៦៥, អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយម, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៥, "ផ្កាញ់មារ",កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ, លេខ១០, ទំ.២៨-៣០, យសោធរ, ភ្នំពេញ

អ៊ឹង មរកត

២០១៧, ពិចារណាលើចម្លាក់ព្រះពុទ្ធបដិមាចតុទិសរវាងស.វ.ទី១៣ និងស.វ.ទី១៦, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត